វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ឯកសារស្រាវជ្រាវសង្ខេប

គណៈកម្មការទី៦ រដ្ឋសភា

# នីតិកម្ម និងវិស័យយុត្តិធម៌ នៅប្រទេសឥណ្ឌូនេស៊ី និងកម្ពុជា


| | | | |
|---|---|---|---|
| អ្នកនិពន្ធ៖ | លោក **មូសារ អ៊ីស្សាម** | ប្រធានផ្នែកស្រាវជ្រាវ (វ.ស.ក) |
| | លោក **ឈន ហាំ** | មន្ត្រីអគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា) |
| | កញ្ញា **វង្ស ចន្ទរស្មីដារា** | មន្ត្រីអគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា) |


កញ្ញា ឆ្នាំ២០១៩


ការិយាល័យរបស់វិទ្យាស្ថានសភាកម្ពុជា៖ ផ្ទះលេខ ៣២ ផ្លូវលេខ ៩ សង្កាត់ទន្លេបាសាក់ រាជធានីភ្នំពេញ
និងនៅក្នុងបរិវេណព្រឹទ្ធសភា វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
+855 (0) 23 210 055/6 | admin@pic.org.kh | www.pic.org.kh

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការ ផ្តល់នូវឯកសារស្រាវជ្រាវតបតាមសំណើរបស់សមាជិក សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារនេះផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ ។

ខ្លឹមសារនៃឯកសារនេះមានកំណត់កាលបរិច្ឆេទច្បាស់លាស់ ដើម្បីផ្តល់ជាឯកសារជំនួយស្មារតីតបតាមម្ចាស់សំណើ ។ ឯកសារនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬគោលនយោបាយណាមួយឡើយ ដោយផ្តោតតែលើព័ត៌មានពីឯកសារដែលមានស្រាប់ និងមិនបានសិក្សាឱ្យ គ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបទៅនឹងបញ្ហាលម្អិតនៃការស្រាវជ្រាវសង្ខេបនោះទេ ពោលគឺដើម្បីឆ្លើយតបទៅនឹងសំណើដែលទទួលបានតែប៉ុណ្ណោះ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំចងក្រងឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថានសភាកម្ពុជា។

©រក្សាសិទ្ធិ ឆ្នាំ២០១៩ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


តារាង .......... ii

រូបភាព .......... ii

១. សេចក្តីផ្តើម .......... 1

២. ប្រព័ន្ធសភា និងដំណើរការការអនុម័តច្បាប់នៅឥណ្ឌូនេស៊ី .......... 1

២.១ ប្រព័ន្ធសភា .......... 1

២.២ តួនាទីនិងមុខងារ .......... 2

២.២.១ សភាតំណាងរាស្ត្រ (DPR) .......... 2

២.២.២ សភាតំណាងតំបន់ (DPD) .......... 3

២.២.៣ សភាប្រឹក្សាប្រជាជន (MPR) .......... 3

២.៣ ដំណើរការនីតិកម្ម .......... 4

៣. សភា និងប្រព័ន្ធថវិការដ្ឋនៅឥណ្ឌូនេស៊ី .......... 4

៣.១ ប្រព័ន្ធថវិកាជាតិ .......... 4

៣.២ ការធ្វើផែនការថវិកា និងវិមជ្ឈការថ្នាក់ក្រោមជាតិ .......... 6

៤. រចនាសម្ព័ន្ធ និងការបែងចែកថវិកាក្នុងវិស័យយុត្តិធម៌ និង នីតិរដ្ឋនៅកម្ពុជា និងឥណ្ឌូនេស៊ី .......... 7

៤.១ រចនាសម្ព័ន្ធវិស័យយុត្តិធម៌នៅកម្ពុជា និងឥណ្ឌូនេស៊ី .......... 7

៤.២ ការបែងចែកថវិកាជាតិក្នុងវិស័យយុត្តិធម៌នៅកម្ពុជា និងឥណ្ឌូនេស៊ី .......... 9

៥. រចនាសម្ព័ន្ធ និងថវិកានៅក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា និងឥណ្ឌូនេស៊ី .......... 10

៦. សន្និដ្ឋាន .......... 12

ឯកសារយោង .......... 13

# តារាង

តារាង ៤-១៖ របនាសម្ព័ន្ធវិស័យយុត្តិធម៌នៅប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី ....................................................8
តារាង ៥-១៖ ស្ថាប័នប្រឆាំងអំពើពុករលួយនៅកម្ពុជា និងឥណ្ឌូនេស៊ី............................................................11
តារាង ៥-២៖ ចំណាយលើក្រុមការងារប្រឆាំងអំពើពុករលួយនៅប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី...........................11

# រូបភាព

រូបភាព ៣-១៖ តម្លាភាព និងសិទ្ធិអំណាចថវិការបស់សភា ................................................................................6
រូបភាព ៣-២៖ ចំណាយថវិកាតាមកម្រិតរដ្ឋាភិបាល ..........................................................................................7
រូបភាព ៤-១៖ ទំហំចំណែក នៃចំណាយរបស់ស្ថាប័ននីតិរដ្ឋ នៅឥណ្ឌូនេស៊ី និងកម្ពុជា......................................9

## ១. សេចក្តីផ្តើម

ឥណ្ឌូនេស៊ី គឺជាប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេនៅអាស៊ីអាគ្នេយ៍ និងជាប្រទេសទី១០ ដែលមានសេដ្ឋកិច្ចធំជាងគេនៅលើពិភពលោក ដោយវាស់វែងដោយអំណាចនៃការទិញ(purchasing power parity)។ ប្រទេសនេះជាប្រទេសមានប្រាក់ចំណូលមធ្យមដែលកំពុងរីកលូតលាស់ ដែលផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗបានកើនជិតប្រាំដងក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ពោលគឺកើនពី ៨០៧ដុល្លារអាមេរិក ក្នុងឆ្នាំ២០០០ ដល់ ៣៨៧៧ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨[1]។ ភាគរយនៃចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រគឺ ១០,៦% ក្នុងឆ្នាំ២០១៧ [2]។

សេដ្ឋកិច្ចឥណ្ឌូនេស៊ីបានកើនឡើងជាមធ្យម ៥,៣% ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ និងត្រូវបានគេរំពឹងថាអត្រានេះនឹងបន្តរហូតដល់ឆ្នាំ២០២៣[3]។ ជាមួយនឹងប្រាក់ចំណូលកើនឡើងយ៉ាងឆាប់រហ័ស និងមានចំនួនប្រជាជនច្រើនជាងគេលំដាប់ទីបួននៅលើពិភពលោកប្រមាណជាង ២៦៧លាននាក់ ឥណ្ឌូនេស៊ីកំពុងក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចធំលំដាប់ទី៥ នៅលើពិភពលោកនៅឆ្នាំ២០៣០ និងជាប្រទេសមានសេដ្ឋកិច្ចធំជាងគេលំដាប់ទី៤ នៅឆ្នាំ២០៥០[4]។

ប្រទេសឥណ្ឌូនេស៊ីមានខេត្តចំនួន៣៤ ចែកចេញជា ៤១៦តំបន់ ទីក្រុងចំនួន៩៨ ស្រុកចំនួន ៧ ២១៧ និងភូមិចំនួន ៨៣ ៣៤៤ ដែលមានអត្តសញ្ញាណជនជាតិភាគតិច វប្បធម៌ និងភាសាចម្រុះ[5]។

យោងតាមចំណាត់ថ្នាក់នីតិរដ្ឋរបស់គម្រោងយុត្តិធម៌ពិភពលោក (World Justice Project) នីតិរដ្ឋនៅប្រទេសឥណ្ឌូនេស៊ីជាប់ចំណាត់ថ្នាក់លេខ៦២ ក្នុងចំណោម១២៦ប្រទេសនៅឆ្នាំ២០១៩។ ចំណាត់ថ្នាក់លម្អិតបានបង្ហាញថាយុត្តិធម៌ផ្នែករដ្ឋប្បវេណី ក្នុងប្រទេសឥណ្ឌូនេស៊ីឈរនៅលំដាប់ទី១០២ ផ្នែកព្រហ្មទណ្ឌឈរនៅលំដាប់ទី៨៦ ការគោរពសិទ្ធិជាមូលដ្ឋានឈរនៅលំដាប់ទី ៨២ និងការអនុវត្តបទប្បញ្ញត្តិនៅលំដាប់ទី៤៣[6]។

ការប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងប្រទេសឥណ្ឌូនេស៊ីមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ យោងតាមសន្ទស្សន៍ការយល់ឃើញអំពីអំពើពុករលួយ របស់អង្គការតម្លាភាពអន្តរជាតិ ប្រទេសឥណ្ឌូណេស៊ីបានកើនពីចំណាត់ថ្នាក់ទាបជាងគេបំផុតក្នុងឆ្នាំ១៩៩៨ ទៅចំណាត់ថ្នាក់ទី៨៩ ក្នុងចំណោម ១៨០ប្រទេសក្នុងឆ្នាំ២០១៨ [7]។

## ២. ប្រព័ន្ធសភា និងដំណើរការការអនុម័តច្បាប់នៅឥណ្ឌូនេស៊ី

### ២.១ ប្រព័ន្ធសភា

ឈ្មោះដំបូងរបស់សភានៃប្រទេសឥណ្ឌូណេស៊ីគឺ "សភាប្រឹក្សាប្រជាជន" (ជាភាសាអង់គ្លេស៖ People's Consultative Assembly) ដែលគេស្គាល់ជាអក្សរកាត់ឥណ្ឌូណេស៊ីថា MPR (Majelis Permusyawarahan Rakyat)។ បន្ទាប់ពីឆ្នាំ២០០៤ សភាប្រឹក្សាប្រជាជន (MPR) ត្រូវបានបែងចែកជា ២សភា គឺសភាតំណាងតំបន់ (ជាភាសាអង់គ្លេស៖ House of Regional Representatives និងជាភាសាឥណ្ឌូនេស៊ី៖ Dewan Perwakilan Rakyat ឬ DPD) និងសភាតំណាងរាស្ត្រ (ជាភាសាអង់គ្លេស៖ House of Representatives និងជាភាសាឥណ្ឌូនេស៊ី៖ Dewan Perwakilan Daerah ឬ DPR) ។ សភាតំណាងរាស្ត្រ (DPR) មានសមាជិកចំនួន ៥៧៥ រូបដែលត្រូវបានជ្រើសរើសចេញពីបញ្ជីគណបក្សនយោបាយយោងតាមប្រព័ន្ធបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស (Open-list proportional representation: PR)។ មណ្ឌលបោះឆ្នោតរបស់សភាតំណាងរាស្ត្រ (DPR) ទទួលបានចំនួនអាសនៈពី ៣ ទៅ ១០។ សភាតំណាងតំបន់ (DPD) មានសមាជិកចំនួន

១៣៦ រូប ដែលត្រូវបានជ្រើសរើសដោយប្រព័ន្ធឆ្នោតតែមួយមិនអាចផ្ទេរបាន (Single-Non-Transferable Vote : SNTV) ។ ខេត្តគឺជាមណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងតំបន់ (DPD) ដែលខេត្តនីមួយៗមាន ៤ អាសនៈដោយមិនគិតពី ចំនួនប្រជាជន។ សមាជិកជាប់ឆ្នោតរបស់សភាតំណាងតំបន់ (DPD) គឺមិនប្រកាន់បក្សពួកនិយមឡើយ ដោយ មានន័យថា សមាជិកនីមួយៗ មិនបានឈរឈ្មោះ អោយគេបោះឆ្នោតអោយ ក្នុងក្របខ័ណ្ឌគណបក្សនយោបាយ ណាមួយ។

សមាជិកនៃសភាតំណាងរាស្ត្រ (DPR) និងសភាតំណាងតំបន់ (DPD) ត្រូវបានជ្រើសរើសដោយការបោះឆ្នោតជាសាកល និងដោយផ្ទាល់ (direct universal suffrage)។ សមាជិកនីមួយៗមានអាណត្តិ រយៈពេល ៥ ឆ្នាំ (ដោយគ្មានការកំណត់ចំនួនអាណត្តិ)។ សភាតំណាងរាស្ត្រ (DPR) ត្រូវបានដឹកនាំដោយប្រធានម្នាក់ និងអនុប្រធានបួននាក់ ដែលត្រូវបានជ្រើសរើសដោយសមាជិកសភារបស់ខ្លួន ចំណែកឯ សភាតំណាងតំបន់ (DPD) ត្រូវបានដឹកនាំដោយប្រធានមួយរូប និងអនុប្រធានពីររូប។

## ២.២ តួនាទីនិងមុខងារ

ជាក់ស្តែងសភាតំណាងរាស្ត្រ (DPR) បំពេញការងារសភាភាគច្រើន។ គណសភាតំណាងរាស្ត្រ(DPR) ប្រជុំជាផ្លូវការទៅតាមការកំណត់ តំណាងរាស្ត្រនៅតែអាចប្រជុំក្នុងកំឡុងចន្លោះ សម័យប្រជុំ គ្រប់ពេលដែលត្រូវការ។ កិច្ចប្រជុំក្នុងចន្លោះសម័យប្រជុំនោះរៀបចំដើម្បីបំពេញ មុខងារសភាតំណាងរាស្ត្រក្នុងការ ត្រួតពិនិត្យតាមដានសកម្មភាពនិតិប្រតិបត្តិ និងដោះស្រាយបញ្ហាថវិកា។ នៅពេលដែលសភាតំណាងរាស្ត្រ (DPR) បំពេញមុខងារ នីតិកម្ម ត្រួតពិនិត្យ និងអនុម័តថវិកាជាតិ សភាក៏អាចចូលរួមក្នុងការបង្កើតនិងអនុវត្តន៍ គោលនយោបាយជាតិផងដែរ។

### ២.២.១ សភាតំណាងរាស្ត្រ (DPR)

តួនាទីរបស់សភាតំណាងរាស្ត្រ (DPR) គឺតាក់តែងអនុម័តច្បាប់នៅថ្នាក់ជាតិ។

សភាតំណាងរាស្ត្រ(DPR) មានគណៈកម្មការចំនួន១១។ គណៈកម្មការចំនួន១១នោះ (ភាសាឥណ្ឌូណេស៊ីហៅថា៖ Komisi) មានដូចខាងក្រោម [20, p. 17]៖

- គណៈកម្មការទី ១៖ ទទួលបន្ទុកកិច្ចការបរទេស កិច្ចការការពារជាតិ ព័ត៌មាននិងទំនាក់ទំនង។
- គណៈកម្មការទី ២៖ ទទួលបន្ទុកកិច្ចការមហាផ្ទៃ ស្វ័យភាពក្នុងតំបន់ និងរដ្ឋបាល។
- គណៈកម្មការទី ៣៖ ទទួលបន្ទុកបញ្ហាច្បាប់ សិទ្ធិមនុស្ស និងសន្តិសុខ។
- គណៈកម្មការទី ៤៖ ទទួលបន្ទុកកសិកម្ម ព្រៃឈើ សមុទ្រនិងជលផល និងអាហារ។
- គណៈកម្មការទី ៥៖ ទទួលបន្ទុកការដឹកជញ្ជូនទូរគមនាគមន៍ សាធារណការ អាគាររដ្ឋ និងការអភិវឌ្ឍជនបទ។
- គណៈកម្មការទី ៦៖ ទទួលបន្ទុកពាណិជ្ជកម្ម ឧស្សាហកម្ម សហករណ៍ សហគ្រាសធុនតូចនិងមធ្យម និងសហគ្រាសរដ្ឋ។
- គណៈកម្មការទី ៧៖ ទទួលបន្ទុកថាមពល ធនធានធម្មជាតិ ការស្រាវជ្រាវ និងបរិស្ថាន។
- គណៈកម្មការទី ៨៖ ទទួលបន្ទុកសាសនា កិច្ចការសង្គម និងស្ត្រី។

- គណៈកម្មការទី ៩៖ ទទួលបន្ទុកប្រជាសាស្ត្រ សុខភាព កម្លាំងពលកម្ម និងការអន្តោប្រវេសន៍។
- គណៈកម្មការទី ១០៖ ទទួលបន្ទុកការអប់រំ យុវជន កីឡា ទេសចរណ៍ និងវប្បធម៌។
- គណៈកម្មការទី ១១៖ ទទួលបន្ទុកហិរញ្ញវត្ថុ ការអភិវឌ្ឍន៍ជាតិ ធនាគារ និងស្ថាប័នមិនមែនហិរញ្ញវត្ថុ។

គណៈកម្មការនីមួយៗមានសមាជិកប្រហែល ៥០ នាក់។ គ្រប់សមាជិកនៃសភាតំណាងរាស្ត្រ(DPR) ត្រូវតែជាសមាជិកនៃគណៈកម្មការណាមួយ។ សមាជិកនីមួយៗមានសិទ្ធចូលជា សមាសភាពនៃគណៈកម្មកាត្រឹមតែមួយ។ សមាសភាពនៃគណៈកម្មការនីមួយៗរៀបចំទៅតាមចំនួនអសនៈដែលគណបក្សនីមួយៗទទួលបាននៅក្នុងសភាតំណាងរាស្ត្រ(គោលការណ៍ សមាមាត្រ) [21, p. 35]។

គណៈកម្មាធិការចំនួន ២ គាំទ្រការងាររបស់គណៈកម្មការទាំង១១៖ មានគណៈកម្មាធិការថវិកាដែលមានមុខងារតែមួយគត់គឺត្រូវពិចារណាលើច្បាប់ដែលកំណត់ថវិកាប្រចាំឆ្នាំរបស់រដ្ឋ និងគណៈកម្មាធិការនីតិកម្ម ដែលមានគោលបំណងពង្រឹងគុណភាពនៃច្បាប់ដែលអនុម័តឡើងដោយសភាតំណាងរាស្ត្រ(DPR) [21, p. 36]។

### ២.២.២ សភាតំណាងតំបន់ (DPD)

សភាតំណាងតំបន់ (DPD) មានតួនាទីផ្តល់មតិទៅលើការតាក់តែងឬធ្វើវិសោធនកម្មលើសេចក្តីព្រាងឬសេចក្តីស្នើច្បាប់ដែលពាក់ព័ន្ធនឹងបញ្ហាថ្នាក់ក្រោមជាតិ [20, p. 17]។ ក្នុងន័យនេះគេអាចកត់សម្គាល់បានថា សភាតំណាងតំបន់ (DPD) មានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់វិមជ្ឈការនៅក្នុងប្រទេសឥណ្ឌូនេស៊ី។

គោលបំណងនៃការបង្កើតសភាតំណាងតំបន់ (DPD) គឺដើម្បីបង្កើនការចូលរួមពីថ្នាក់ក្រោមជាតិ ដូច្នេះសភាតំណាងតំបន់ (DPD) ដើរតួនាទីជាអ្នកតំណាងដើម្បីធានាថា គ្រប់ខេត្តទាំងអស់ ចូលរួមកិច្ចពិភាក្សាជាមួយសភាតំណាងរាស្ត្រ (DPR) និងរដ្ឋាភិបាលដើម្បីផលប្រយោជន៍ល្អបំផុតរបស់ខេត្ត [22, p. 39]។ ដើម្បីងាយស្រួលក្នុងការទំនាក់ទំនងជាមួយម្ចាស់សន្លឹកឆ្នោត សភាតំណាងតំបន់ (DPD) បានបើកការិយាល័យនៅគ្រប់ខេត្តទាំងអស់ក្នុងប្រទេសឥណ្ឌូនេស៊ី ដោយអនុលោមតាមច្បាប់លេខ ២៧/២០០៩ ។ តាមច្បាប់នេះ សភាតំណាងតំបន់ (DPD) ទទួលខុសត្រូវ ក្នុងការបង្កើតការិយាល័យនៅក្នុងខេត្ត។ ការិយាល័យរបស់សភាតំណាងតំបន់ (DPD) នៅតាមបណ្តាខេត្តនានា ជួយប្រមូលព័ត៌មាន និងការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ដូចជារដ្ឋាភិបាលថ្នាក់តំបន់(regional governments) និងអង្គការក្រៅរដ្ឋាភិបាល។ ការិយាល័យរបស់សភាតំណាងតំបន់ (DPD) ក៏ផ្តល់កន្លែងប្រជុំសម្រាប់សមាជិករបស់សភាតំណាងតំបន់ (DPD) និងសហគមន៍មូលដ្ឋានដើម្បីទទួលនិងពិភាក្សាអំពីបណ្តឹងតវ៉ាផ្សេងៗពីសាធារណជន។

### ២.២.៣ សភាប្រឹក្សាប្រជាជន (MPR)

បច្ចុប្បន្ន តួនាទីចំបងរបស់ សភាប្រឹក្សាប្រជាជន(MPR) គឺធ្វើការប្រគល់តំណែង និងចោទប្រកាន់ប្រធានាធិបតី និងអនុប្រធានាធិបតីឥណ្ឌូនេស៊ី ក៏ដូចជាទទួលខុសត្រូវ លើការធ្វើវិសោធនកម្ម ឬលុបចោលមាត្រាមួយចំនួន ឬបទប្បញ្ញត្តិ នៃរដ្ឋធម្មនុញ្ញ [20, p. 17]។ សភាប្រឹក្សាប្រជាជន (MPR) ត្រូវបានផ្សំឡើងដោយសមាជិកនៃសភាទាំងពីរ សភាតំណាងរាស្ត្រ(DPR) និង សភាតំណាងតំបន់ (DPD) ដែលចូលរួមជាមួយគ្នានៅក្នុងសភាតែមួយ [21, p. 31]។ យោងតាមរដ្ឋធម្មនុញ្ញប្រធានាធិបតីនិងអនុប្រធានាធិបតី អាចត្រូវបានចោទប្រកាន់និងដកខ្លួនចេញ ពីមុខតំណែង ប្រសិនបើពួកគេត្រូវបានគេចាត់

ទុកថា មិនសមនឹងបំពេញភារកិច្ចរបស់ខ្លួន ហើយបានប្រព្រឹត្តបទឧក្រិដ្ឋដូចជា អំពើពុករលួយ ឬការក្បត់ជាតិ។ នីតិវិធីចោទប្រកាន់នេះ មានដំណាក់កាលផ្សេងៗគ្នា ហើយត្រូវបានបញ្ចប់នៅពេល សភាប្រឹក្សាប្រជាជន (MPR) បោះឆ្នោតដើម្បីសំរេចដកតំណែងប្រធានាធិបតី ឬអនុប្រធានចេញ។

### ២.៣ ដំណើរការនីតិកម្ម

យោងតាមគេហទំព័រផ្លូវការរបស់សភាតំណាងរាស្ត្រ(DPR) សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់នីមួយៗ ត្រូវការការយល់ព្រមរួមគ្នាពីប្រធានាធិបតីនិងសភាតំណាងរាស្ត្រ(DPR) បន្ទាប់ពីការពិគ្រោះគ្នា។ សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ ដែលត្រូវបានអនុម័តហើយ ត្រូវដាក់ជូនដោយថ្នាក់ដឹកនាំសភាតំណាងរាស្ត្រ(DPR) ទៅប្រធានាធិបតី ដើម្បីប្រកាសឱ្យប្រើក្នុងរយៈពេលថ្ងៃការងារចំនួនប្រាំពីរថ្ងៃ[1]។ ប្រសិនបើប្រធានាធិបតីមិនចុះហត្ថលេខាក្នុងរយៈពេល ៣០ ថ្ងៃ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក៏នៅតែចូលជាធរមាន ក្រោយពីរយៈពេលនោះ [23]។

សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់អាចចេញពីប្រធានាធិបតី សភាតំណាងរាស្ត្រ(DPR) ឬសភាតំណាងតំបន់ (DPD) ។ ទោះបីជាយ៉ាងណាក៏ដោយ សភាតំណាងតំបន់ (DPD) អាចធ្វើសំណើរទៅ សភាតំណាងរាស្ត្រ(DPR) លើសេចក្តីព្រាងឬសេចក្តីស្នើច្បាប់ ទាក់ទងនឹង ស្វ័យភាពខេត្ត (regional autonomy) ការអភិវឌ្ឍក្នុងខេត្ត ការទំនាក់ទំនងរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលក្នុងតំបន់ (regional governments) ពាក់ព័ន្ធទៅនឹងបញ្ហាហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានជាតិ និងតុល្យភាពសារពើពន្ធរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលក្នុងតំបន់ [20, p. 17]។

សភាជាន់ខ្ពស់កម្ពុជា(ព្រឹទ្ធសភា) នឹងសភាតំណាងតំបន់នៅឥណ្ឌូនេស៊ី(DPD) មានភាពខុសគ្នា។ នៅប្រទេសកម្ពុជាព្រឹទ្ធសភាមានអំណាចក្នុងការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ប៉ុន្តែមិនអាចជំទាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលបានអនុម័តយល់ព្រមបន្ទាប់ពីការពិនិត្យចុងក្រោយដោយសភាជាន់ទាប (រដ្ឋសភា) ឡើយ[3]។ ភាពខុសគ្នាមួយទៀតគឺសមាជិកនៃសភាតំណាងតំបន់(DPD) ត្រូវបានជ្រើសរើសដោយការបោះឆ្នោតផ្ទាល់ រីឯសមាជិកព្រឹទ្ធសភានៅកម្ពុជាត្រូវបានជ្រើសរើសដោយការបោះឆ្នោតដោយប្រយោល។ លើសពីនេះ ព្រឹទ្ធសភាកម្ពុជា អាចស្នើសុំបង្កើតច្បាប់ ខណៈដែលសភាតំណាងតំបន់(DPD)នៃឥណ្ឌូនេស៊ីអាចស្នើសុំបង្កើតច្បាប់ដែលទាក់ទងទៅនឹងបញ្ហាជាក់លាក់នៅក្នុងខេត្តប៉ុណ្ណោះ។

## ៣. សភា និងប្រព័ន្ធថវិការដ្ឋនៅឥណ្ឌូនេស៊ី

### ៣.១ ប្រព័ន្ធថវិកាជាតិ

ប្រទេសឥណ្ឌូនេស៊ីកំពុងស្ថិតក្នុងដំណាក់កាលនៃការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេល ២០ឆ្នាំ ដែលបានចាប់ផ្តើម ពីឆ្នាំ២០០៥ និងបញ្ចប់នៅឆ្នាំ២០២៥ ។ ស្រដៀងទៅនឹងយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិរបស់ប្រទេសកម្ពុជាដែរ ផែនការនេះត្រូវបានធ្វើឡើងលម្អិតជាដំណាក់កាល សម្រាប់អាទិភាពរយៈពេលប្រាំឆ្នាំ។ បច្ចុប្បន្ននេះ រដ្ឋាភិបាលឥណ្ឌូនេស៊ីកំពុងស្ថិតក្នុងដំណាក់កាលទីបី ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីជំនួយសង្គមទាក់ទងនឹងការអប់រំ និងការថែទាំសុខភាព[8]។

ក្នុងចំណោមបណ្ដាសភានៅតាមបណ្ដាប្រទេសអាស៊ាន សភាតំណាងរាស្ត្ររបស់ឥណ្ឌូនេស៊ី ជាស្ថាប័នមានអំណាចខ្លាំងបំផុតលើការអនុម័តថវិកាជាតិ ដែលមានអំណាចគ្មានដែនកំណត់ក្នុងការផ្លាស់ប្ដូរចំណូល និងចំណាយថវិកា អាស្រ័យលើវិន័យនៃការខ្ចី និងឱនភាពថវិកាជាតិ និងអាស្រ័យលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀងរួមជាមួយប្រធានាធិបតី (គ្មានប្រធានាធិបតីឥណ្ឌូនេស៊ីណាម្នាក់បដិសេធការផ្ដល់សច្ចាប័នលើច្បាប់ថវិកាប្រចាំឆ្នាំទេ ចាប់តាំងពី " យុគសម័យថ្មី"ដែលបានចាប់ផ្ដើមក្នុងឆ្នាំ១៩៩៨)។ សភាតំណាងតំបន់មិនមានតួនាទីក្នុងការអនុម័តសេចក្ដីស្នើច្បាប់ថវិកាទេ[១]។

គណៈកម្មាធិការថវិកានៃសភាតំណាងរាស្ត្រ គឺជាគណៈកម្មាធិការធំជាងគេមួយ ក្នុងចំណោមគណៈកម្មាធិការនៅអាស៊ាន ដែលជា"គណៈកម្មការមួយនៃគណៈកម្មការជាច្រើន" ដែលមានសមាជិកសភាប្រមាណ ១០០ នាក់តំណាងឱ្យគណៈកម្មការវិស័យទាំង១១ ដែលពិនិត្យលើបញ្ហាទាក់ទងនឹងថវិកា។ គណៈកម្មាធិការនេះធ្វើការពិភាក្សាជាបឋមទៅលើសំណើថវិកាជាតិ ផ្ដល់យោបល់សម្រេចលើថវិកា និងពិភាក្សាអំពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍របស់អាជ្ញាធរសវនកម្មជាន់ខ្ពស់ស្ដីពីការអនុវត្តថវិកាជាតិ។ ពួកគេជារឿយៗកោះហៅរដ្ឋមន្ត្រី និងមន្ត្រី រដ្ឋាភិបាលមកចំពោះមុខគណៈកម្មាធិការ និងធ្វើការផ្សព្វផ្សាយសវនការជាសាធារណៈដោយមានការចូលរួមពីបណ្ដាញសារព័ត៌មាន។

ដើម្បីជួយគណៈកម្មាធិការតាមរយៈនីតិវិធីច្បាប់ថវិកាជាតិ សភាតំណាងរាស្ត្រមានមន្ត្រីមួយចំនួនធំជួយផ្ដល់ការវិភាគស៊ីជម្រៅអំពីថវិកា ជូនដល់សមាជិកសភា។ គណៈកម្មការនីមួយៗដែលទទួលបន្ទុកលើវិស័យទាំង១១ មានមន្ត្រីប្រាំរូប (សរុបទាំងអស់មាន ៥៥រូប) និងគណៈកម្មាធិការថវិកាមានមន្ត្រី ១០រូប។ គណៈកម្មាធិការថវិកាក៏ត្រូវបានផ្ដល់ជំនួយផងដែរដោយលេខាធិការដ្ឋានថវិកា ដែលជាការិយាល័យវិភាគថវិកា និងការអនុវត្តថវិការជាតិ មានមន្ត្រីចំនួន ៣០រូប។

យោងតាមការសិក្សារបស់សមាគមអន្តរសភាអាស៊ាន (AIPA) ដំណើរការថវិកានៅប្រទេសឥណ្ឌូនេស៊ីមានតម្លាភាព និងមានគណនេយ្យភាពជាងគេបំផុតនៅក្នុងអាស៊ាន ដោយផ្អែកលើលក្ខណៈមួយចំនួនដូចខាងក្រោម[១]:

- រដ្ឋាភិបាលដាក់របាយការណ៍ "គោលនយោបាយសារពើពន្ធ និងអាទិភាពថវិកា" មុនច្បាប់ថវិកា ទៅជូនសភា ដែលរួមមានការពិពណ៌នាអំពី ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធ និងអាទិភាព គោលដៅឱនភាពថវិកា ការព្យាករណ៍ចំណូល និងសំណើពិដានចំណាយ សម្រាប់ឆ្នាំក្រោយ។
- សេចក្ដីព្រាងច្បាប់ស្ដីពី ថវិកាដែលត្រូវបានដាក់ជូនសភា រួមមាន ក្របខ័ណ្ឌថវិការយៈពេលមធ្យមដែលត្រូវបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ដែលស្របតាមថវិកា និងត្រូវបានផ្សព្វផ្សាយជាសាធារណៈ។
- ថវិកានេះក៏រួមបញ្ចូលផងដែរនូវ "របាយការណ៍ស្ដីពី ហានិភ័យសារពើពន្ធ" ការវិភាគចំណាយពន្ធនិងព័ត៌មានអំពីការអនុវត្ត ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ។
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ត្រូវបានបោះពុម្ពផ្សាយក្នុងរយៈពេលប្រាំមួយខែនៃដំណាច់ឆ្នាំសារពើពន្ធ។

រូបភាពទី ៣-១ បង្ហាញថា ប្រទេសឥណ្ឌូនេស៊ីស្ថិតនៅកំពូលតារាងដែលមាន សន្ទស្សន៍តម្លាភាពនិងសិទ្ធិអំណាចថវិកាខ្ពស់ (សមត្ថភាពសភាក្នុងការជះឥទ្ធិពលលើថវិកា) យោងតាមការវាយតម្លៃរបស់ AIPA ស្ដីពី សភាអាស៊ាន។

រូបភាព ៣-១៖ តម្លាភាព និងសិទ្ធិអំណាចថវិការបស់សភា




*ប្រភព៖ អន្តរសភាអាស៊ាន ២០១៥[9]*

### ៣.២ ការធ្វើផែនការថវិកា និងវិមជ្ឈការថ្នាក់ក្រោមជាតិ

ការអនុម័តថវិកាជាតិរបស់សភា ធ្វើឡើងពីរខែមុនពេលឆ្នាំសារពើពន្ធថ្មីចាប់ផ្តើម។ ការអនុម័តសំណើថវិកាបានធាប់ អនុញ្ញាតឱ្យសភាថ្នាក់ក្រោមជាតិព្យាករណ៍អំពីការផ្ទេរថវិកា ដើម្បីបញ្ចប់ និងអនុម័តថវិការបស់ពួកគេមុនពេលចាប់ផ្តើមនៃឆ្នាំសារពើពន្ធថ្មី។

ប្រទេសឥណ្ឌូនេស៊ីស្ថិតក្នុងចំណោមបណ្តាប្រទេសដែលមានវិមជ្ឈការខ្លាំងជាងគេនៅអាស៊ាន និងពិភពលោក។ បន្ទាប់ពីចលនាវិមជ្ឈការ "Big Bang" ពីឆ្នាំ ១៩៩៨ ដល់ ២០០១ រដ្ឋាភិបាលមូលដ្ឋានរបស់ខ្លួនចំនួន ៤០០ (ដែលបច្ចុប្បន្នមានចំនួន ៥០៨ រួមទាំងថ្នាក់តំបន់ និងក្រុង) ត្រូវបានផ្តល់ការទទួលខុសត្រូវលើ កិច្ចការសាធារណៈ ការថែទាំសុខភាព ការអប់រំ កិច្ចការវប្បធម៌និងសង្គម ពលកម្ម ការពារបរិស្ថាន ដីធ្លី កិច្ចការប្រជាពលរដ្ឋនិងការវិនិយោគ យុវជននិងកីឡា ទូរគមនាគមន៍ លំនៅដ្ឋាន និងការដឹកជញ្ជូន[10]។ ស្ទើរតែ ៣០%នៃចំណាយនៅក្នុងប្រទេសឥណ្ឌូនេស៊ី គឺជាចំណាយថ្នាក់ក្រោមជាតិ ដែលចំណាយថ្នាក់ក្រោមជាតិនេះមានត្រឹមតិចជាង ១០%ក្នុងប្រទេសកម្ពុជា (រូបភាព ៣-២)។

រូបភាព ៣-២ ចំណាយថវិកាតាមកម្រិតរដ្ឋាភិបាល (គិតជាភាគរយនៃផ.ស.ស)




*ប្រភព៖ ច្បាប់ទូទាត់ថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៥-២០១៧ និងច្បាប់ថវិកាជាតិឆ្នាំ២០១៨-២០១៩; ច្បាប់ទូទាត់ថវិកាជាតិរបស់សាធារណៈរដ្ឋឥណ្ឌូនេស៊ីឆ្នាំ២០១៥-២០១៦ និងច្បាប់ថវិកាជាតិរបស់សាធារណៈរដ្ឋឥណ្ឌូនេស៊ីឆ្នាំ២០១៦-២០១៩* [11, 12, 13]

រដ្ឋាភិបាលថ្នាក់ជាតិបានរក្សាការទទួលខុសត្រូវសម្រាប់តែ ផ្នែកសន្តិសុខជាតិ គោលនយោបាយការបរទេស យុត្តិធម៌ អភិបាលកិច្ចនិងផែនការ និងកិច្ចការសាសនាប៉ុណ្ណោះ។ សភាថ្នាក់ក្រោមជាតិមានផែនការថវិការបស់ខ្លួន ប៉ុន្តែរដ្ឋាភិបាលមូលដ្ឋានត្រូវដាក់ស្នើថវិការបស់ខ្លួន ហើយត្រូវអនុម័តដោយរដ្ឋាភិបាលថ្នាក់ជាតិ។ រដ្ឋាភិបាលមូលដ្ឋាន ត្រូវបានដាក់កំហិតលើការខ្ចីប្រាក់ រួមទាំងការហាមឃាត់ទាំងស្រុងលើការខ្ចីប្រាក់ពីបរទេស។

ជារួម វិស័យទូទៅរបស់រដ្ឋាភិបាលមានតួនាទីធំ និងកើនឡើងជាលំដាប់នៅក្នុងប្រទេសកម្ពុជាប្រមាណ ២៥% នៃ ផ.ស.ស បើប្រៀបធៀបទៅនឹង ប្រហែល ១៥% ដែលមានស្ថិរភាព នៅក្នុងប្រទេសឥណ្ឌូនេស៊ី។

## ៤. រចនាសម្ព័ន្ធ និងការបែងចែកថវិកាក្នុងវិស័យយុត្តិធម៌ និង នីតិរដ្ឋនៅកម្ពុជា និងឥណ្ឌូនេស៊ី

### ៤.១ រចនាសម្ព័ន្ធវិស័យយុត្តិធម៌នៅកម្ពុជា និងឥណ្ឌូនេស៊ី

តារាង ៤-១ ប្រៀបធៀបស្ថាប័នដែលលើកកម្ពស់នីតិរដ្ឋនៅប្រទេសឥណ្ឌូនេស៊ី និងប្រទេសកម្ពុជា។ ប្រទេសទាំងពីរមានស្ថាប័នមួយចំនួនដូចគ្នា ឧទាហរណ៍៖ គណៈកម្មការលុបបំបាត់អំពើពុករលួយនៅឥណ្ឌូនេស៊ី (ជាភាសាឥណ្ឌូនេស៊ីហៅកាត់ថា KPK ឈ្មោះពេញ Komisi Pemberantasan Korupsi) និងអង្គភាពប្រឆាំងអំពើពុករលួយនៅកម្ពុជា (ACU)។

យ៉ាងណាមិញ ឥណ្ឌូនេស៊ីមានស្ថាប័នមួយចំនួនទៀតដែលកម្ពុជាមិនមាន។ ជាឧទាហរណ៍៖ ឥណ្ឌូនេស៊ីមានតុលាការសិទ្ធិមនុស្សអចិន្ត្រៃយ៍ ដែលទទួលបន្ទុកកាត់ក្តីលើសំណុំរឿងពាក់ព័ន្ធនឹងករណីរំលោភបំពានសិទ្ធិមនុស្សដូចជា៖ បទល្មើសប្រល័យពូជសាសន៍ និងបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងមនុស្សជាតិ។ តុលាការនេះស្រដៀងនឹងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC) ដែលនឹងរំលាយទៅវិញនៅពេលដែលសាលាក្តីខ្មែរក្រហមធ្វើចប់សព្វគ្រប់[14]។

ឥណ្ឌូនេស៊ី មានផងដែរនូវការិយាល័យប្រជាពលរដ្ឋ (Ombudsman office) នៅស្ទើរគ្រប់ខេត្តទាំងអស់ ដើម្បីដោះស្រាយពាក្យបណ្តឹងរបស់សាធារណជនអំពីអំពីសេវារដ្ឋាភិបាល រួមមានពាក្យបណ្តឹងទាក់ទងនឹង ការធ្វេសប្រហែស ការមិនយកចិត្ត

ទុកដាក់ ការប្រព្រឹត្តផ្ទុយពីច្បាប់ និងអំពើពុករលួយ។ ខណៈដែលកម្ពុជាក៏មានការិយាល័យប្រជាពលរដ្ឋ និងយន្តការទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋនៅតាមស្រុកមួយចំនួន ប៉ុន្តែការិយាល័យនេះហាក់ពុំមានថវិកាស្វយ័តសម្រាប់អនុវត្តការងារនេះនៅឡើយទេ[4]។

ឥណ្ឌូនេស៊ីមានទីភ្នាក់ងារគាំពារជនរងគ្រោះ និងសាក្សី ដែលជាស្ថាប័នការពារសុវត្ថិភាពជូនជនរងគ្រោះ និងសាក្សីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ជាពិសេសនៅពេលដែលពួកគេផ្តល់សក្ខីកម្មដល់តុលាការ។ សិទ្ធិរបស់ជនរងគ្រោះ និងសាក្សីនៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលផ្តល់អោយតាមរយៈទីភ្នាក់ងារនេះរួមមាន ការការពារដល់សាក្សី ជនរងគ្រោះ ទ្រព្យសម្បត្តិ និងក្រុមគ្រួសាររបស់ពួកគេ សិទ្ធិទទួលបានព័ត៌មានអំពីសំណុំរឿង និងសេចក្តីសម្រេចរបស់តុលាការ សិទ្ធិទទួលបានការប្រឹក្សាយោបល់ផ្នែកច្បាប់ និងសិទ្ធិទទួលបានអត្តសញ្ញាណថ្មី។ ជនរងគ្រោះនៃបទឧក្រិដ្ឋមួយចំនួនអាចទទួលបានសំណងពីរដ្ឋាភិបាលទៀតផង [15]។

**តារាង ៤-១: រចនាសម្ព័ន្ធវិស័យយុត្តិធម៌នៅប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី**

| ឥណ្ឌូនេស៊ី | កម្ពុជា |
|---|---|
| តុលាការ | តុលាការ |
| តុលាការធម្មនុញ្ញ | ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| គណៈកម្មការតុលាការ | ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម |
| ការិយាល័យអគ្គព្រះរាជអាជ្ញា | នាយកដ្ឋានអយ្យការ |
| ក្រសួងទទួលបន្ទុកសិទ្ធិមនុស្ស និងច្បាប់ | ក្រសួងយុត្តិធម៌ |
| នគរបាលជាតិឥណ្ឌូនេស៊ី | នគរបាលយុត្តិធម៌ |
| គណៈកម្មការលុបបំបាត់អំពើពុករលួយ | អង្គភាពប្រឆាំងអំពើពុករលួយ |
| គណៈកម្មការជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស | គណៈកម្មការធិការសិទ្ធិមនុស្សកម្ពុជា |
| តុលាការអចិន្ត្រៃយ៍ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស | ពុំមានតុលាការអចិន្ត្រៃយ៍ទទួលបន្ទុកផ្នែកសិទ្ធិមនុស្សទេ |
| ក្រុមអ្នកជំនាញផ្នែកច្បាប់ | រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ |
| គណៈកម្មការជំនាញនៅស្ថាប័នសភា | គណៈកម្មការជំនាញនៅស្ថាប័នសភា |
| ទីភ្នាក់ងារការពារជនរងគ្រោះ និងសាក្សី | ពុំមានទីភ្នាក់ងារការពារជនរងគ្រោះ និងសាក្សីទេ |
| ការិយាល័យអង្កេត និងទទួលពាក្យបណ្តឹងរបស់ឥណ្ឌូនេស៊ី | ការិយាល័យអង្កេត និងទទួលពាក្យបណ្តឹង ប៉ុន្តែពុំមានថវិកាស្វយ័តទេ |
| គណៈកម្មាធិការរៀបចំការបោះឆ្នោត | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |

*ប្រភព៖ បច្ចុប្បន្នភាពស្តីពីនីតិរដ្ឋដើម្បីសិទ្ធិមនុស្សនៅអាស៊ាន៖ មាគ៌ាឆ្ពោះទៅកាន់សមាហរណកម្ម ឥណ្ឌូនេស៊ី៖ មជ្ឈមណ្ឌលធនធានសិទ្ធិមនុស្ស (2016)[15]*

## ៤.២ ការបែងចែកថវិកាជាតិក្នុងវិស័យយុត្តិធម៌នៅកម្ពុជា និងឥណ្ឌូនេស៊ី

ទិន្នន័យរបស់ប្រទេសឥណ្ឌូនេស៊ីនៅមានកម្រិត ដែលជាឧបសគ្គដល់ការធ្វើការសិក្សាស្រាវជ្រាវភ្លាមៗ (ទោះបីជាតម្លាភាពនៅក្នុងការប្រើប្រាស់ថវិកាជាតិនៅឥណ្ឌូនេស៊ីមានកម្រិតខ្ពស់ ទិន្នន័យភាគច្រើនត្រូវបានបោះផ្សាយជាភាសាឥណ្ឌូនេស៊ី ដែលទាមទារអោយមានការបកប្រែ និងតម្រូវអោយមានជំនួយបច្ចេកទេសពីអ្នកជំនាញក្នុងស្រុករបស់ឥណ្ឌូនេស៊ីជាចាំបាច់)។ ទិន្នន័យជារួមមួយចំនួនត្រូវបានបោះផ្សាយជាសាធារណៈពីប្រភពអន្តរជាតិ ប៉ុន្តែអាចមានការយឺតយ៉ាវ ដែលបច្ចុប្បន្នមានត្រឹមឆ្នាំ២០១៤។

រូបភាព៤-១ ខាងក្រោមប្រៀបធៀបពីធនធានរបស់វិស័យយុត្តិធម៌។ នៅក្នុងចំណោមស្ថាប័នទាំងប្រាំមួយរបស់ឥណ្ឌូនេស៊ី ក្រសួងទទួលបន្ទុកផ្នែកច្បាប់ និងសិទ្ធិមនុស្សទទួលបានថវិកាជាតិច្រើនជាងគេ គឺ ០,៤៤% ជាមធ្យមនៃចំណាយថ្នាក់ជាតិសរុបពីឆ្នាំ២០១០-២០១៤ បន្ទាប់មកតុលាការកំពូល ០,៣៧% ជាមធ្យម។ ស្ថាប័នអយ្យការកំពូល ទទួលបានប្រហែល ០,២៣% ជាមធ្យមពីឆ្នាំ២០១០-២០១៤ ខណៈដែលតុលាការធម្មនុញ្ញទទួលបានត្រឹម ០,០១%ប៉ុណ្ណោះ។

នៅក្នុងចំណោមស្ថាប័នទាំងប្រាំរបស់កម្ពុជា ទំហំចំណាយរបស់សាលាដំបូងរាជធានី ខេត្ត មានចំណែកធំជាងគេ ពោលគឺ ០,២៨% ជាមធ្យមនៃចំណាយថ្នាក់ជាតិសរុបគិតពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ បន្ទាប់មកក្រសួងយុត្តិធម៌ ០,១៧%។ តុលាការកំពូលមានចំណែក ០,០៣% ជាមធ្យមប្រចាំឆ្នាំក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។

**រូបភាព ៤-១: ទំហំចំណែក នៃចំណាយរបស់ស្ថាប័ននីតិរដ្ឋ នៅឥណ្ឌូនេស៊ី និងកម្ពុជា**



*ប្រភព៖ ធនាគារពិភពលោក ទិន្នន័យប្រទេសឥណ្ឌូនេស៊ីៈ ២០១០-២០១៤ និងច្បាប់ទូទាត់ថវិកាជាតិ កម្ពុជាឆ្នាំ២០១៥-២០១៧ និងច្បាប់ថវិកាជាតិឆ្នាំ២០១៨-២០១៩[12, 13, 16]*

## ៥.រចនាសម្ព័ន្ធ និងថវិកានៅក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា និងឥណ្ឌូនេស៊ី

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងឥណ្ឌូនេស៊ីសុទ្ធតែមានកម្មវិធីប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ប្រទេសឥណ្ឌូនេស៊ី មានស្ថាប័នបីដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយគឺ៖ គណៈកម្មការលុបបំបាត់អំពើពុករលួយ តុលាការជាតិប្រឆាំងអំពើពុករលួយ និងការិយាល័យអគ្គព្រះរាជអាជ្ញា។

នៅក្នុងចំណោមស្ថាប័នទាំងនេះ គណៈកម្មការលុបបំបាត់អំពើពុករលួយដើរតួនាទីសំខាន់ជាងគេ និងទទួលបានជោគជ័យគួរអោយកត់សំគាល់។ វាជាទំនួលខុសត្រូវដ៏ធំមួយរបស់ស្ថាប័ននេះដែលបានលើកកម្ពស់ប្រទេសឥណ្ឌូនេស៊ី ពីចំណាត់ថ្នាក់បាតតារាងនៅក្នុងឆ្នាំ ១៩៩៥ មកលេខរៀងទី៨៩ ក្នុងចំណោម ១៨០ប្រទេសក្នុងឆ្នាំ២០១៨ ផ្អែកលើសន្ទស្សន៍នៃការយល់ឃើញអំពីអំពើពុករលួយ របស់អង្គការតម្លាភាពអន្តរជាតិ។

គណៈកម្មការនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០២ ដោយដាក់អោយដំណើរការដោយឯករាជ្យទាំងស្រុង ស្របនឹងសមត្ថកិច្ចរបស់ប៉ូលីសនគរបាលយុត្តិធម៌ ការិយាល័យអគ្គព្រះរាជអាជ្ញា និងប្រព័ន្ធតុលាការ ដោយទទួលបានអំណាចពិសេសនៅក្នុងការស៊ើបអង្កេត និងថតសម្លេងដោយពុំចាំបាច់មានការអនុញ្ញាតពីតុលាការ (ដោយសារតុលាការនៃប្រទេសឥណ្ឌូនេស៊ីខ្លួនឯងកំពុងតែរងគ្រោះដោយសារអំពើពុករលួយ)។ អត្រានៃការផ្តន្ទាទោសធ្វើឡើងដោយគណៈកម្មការមានជិត ១០០ ភាគរយ ដោយបានកាត់ទោសមន្ត្រីសាធារណៈដែលប្រព្រឹត្តអំពើពុករលួយជាង ១ ០០០ នាក់[17]។

នៅប្រទេសកម្ពុជា អង្គភាពប្រឆាំងពំពើពុករលួយ (ACU) គឺជាស្ថាប័នសំខាន់ជាងគេនៅក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ អង្គភាពនេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ២០១០។ តារាងទី ៥-១ បង្ហាញអំពីមុខងាររបស់ស្ថាប័ននីមួយៗខាងលើនៅក្នុងប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី ។

**តារាង ៥-១: ស្ថាប័នប្រឆាំងអំពើពុករលួយនៅកម្ពុជា និងឥណ្ឌូនេស៊ី**

| ឥណ្ឌូនេស៊ី | កម្ពុជា |
|---|---|
| *គណៈកម្មការលុបបំបាត់អំពើពុករលួយ (KPK)* | *អង្គភាពប្រឆាំងអំពើពុករលួយ (ACU)* |
| KPK ស៊ើបអង្កេត និងធ្វើការចោទប្រកាន់នៅចំពោះមុខតុលាការពិសេស ទទួលបន្ទុកកាត់ក្តីលើសំណុំរឿងពុករលួយ មានចៅក្រមទាំងអស់ ៥រូប ដែល៣រូបជាចៅក្រមចំពោះកិច្ចដែលបានជ្រើសតាំងយ៉ាងពិសេសដោយគណៈកម្មាធិការមួយដែលស្ថិតនៅក្រោមតុលាការកំពូល។ | ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតាមរយៈបណ្តឹង និងធ្វើការស៊ើបអង្កេតអំពើពុករលួយគ្រប់ទម្រង់[18]. |
| *តុលាការជាតិប្រឆាំងអំពើពុករលួយ* | *គ្មាន* |
| តុលាការជំនាញនេះទទួលបន្ទុកកាត់ក្តីតែលើសំណុំរឿងពុករលួយប៉ុណ្ណោះ ដែលត្រូវបានបង្កើតឡើងព្រមគ្នាជាមួយគណៈកម្មការលុបបំបាត់អំពើពុករលួយក្នុងឆ្នាំ២០០២។ | |
| *ការិយាល័យអគ្គព្រះរាជអាជ្ញា* | *អគ្គព្រះរាជអជ្ញា* |
| មានតួនាទីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងមានភារកិច្ចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងអនុវត្ត សេចក្តីសម្រេចរបស់ស្ថាប័នតុលាការ ដែលបានបញ្ញត្តិដោយច្បាប់ បូករួមទាំងការស៊ើបអង្កេតរាល់សកម្មភាពដែលទាក់ទងទៅនឹងអំពើពុករលួយ។ | អគ្គព្រះរាជអជ្ញាអាចដំណើរការនីតិវិធីក្តី និងអនុវត្តសេចក្តីសម្រេចចិត្តរបស់ចៅក្រម លើនីតិវិធីដែលត្រូវអនុវត្តដោយបង្ខំ រួមទាំងស៊ើបអង្កេតទៅលើសកម្មភាពបទឧក្រិដ្ឋជាក់ស្តែងពាក់ព័ន្ធអំពើពុករលួយ។ |

*ប្រភព៖ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការតម្លាភាពអន្តរជាតិ ឆ្នាំ២០១៨ [17, 19]*

តារាង ៥-២ បានបង្ហាញពីការចំណាយរបស់ KPK សម្រាប់ប្រជាពលរដ្ឋម្នាក់នៅក្នុងប្រទេសឥណ្ឌូនេស៊ីមានចំនួនប្រហែល ០,១១ដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ ហើយការចំណាយនេះមានលក្ខណៈថេរប្រមាណជា ០,០៣%ធៀបទៅនឹងចំណាយថ្នាក់ជាតិសរុប ។

នៅក្នុងប្រទេសកម្ពុជា ការចំណាយរបស់ ACU សម្រាប់ប្រជាពលរដ្ឋម្នាក់មានប្រហែល ០,៤៨ដុល្លារអាមេរិកក្នុងមួយឆ្នាំៗ និងមានលក្ខណៈថេរប្រមាណ ០,២% នៃចំណាយថ្នាក់ជាតិសរុបក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ។ ទោះបីការចំណាយថវិកាគិតជាប្រាក់ដុល្លារមានលក្ខណៈថេរក្នុងឆ្នាំ២០១៨ វាត្រូវបានរំពឹងថាមានការកើនឡើងដល់ទៅ ៥០%ក្នុងឆ្នាំ២០១៩ [5]។

**តារាង ៥-២: ចំណាយលើក្រុមការងារប្រឆាំងអំពើពុករលួយនៅប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី**

| អង្គភាពប្រឆាំងអំពើពុករលួយនៅកម្ពុជា | 2015 | 2016 | 2017 | 2018 | 2019 | មធ្យមភាគ |
|---|---|---|---|---|---|---|
| ចំណាយ (គិតជាលានដុល្លារអាមេរិក) | 5.9 | 6.7 | 7.6 | 7.6 | 11.5 | 7.9 |
| កំណើន | - | 13% | 13% | 1% | 50% | 19% |

| | | | | | | |
|---|---|---|---|---|---|---|
| ចំណាយសម្រាប់ប្រជាពលរដ្ឋម្នាក់ (គិតជាដុល្លារអាមេរិក) | $0.37 | $0.41 | $0.46 | $0.46 | $0.69 | $0.48 |
| **គណៈកម្មការលុបបំបាត់អំពើពុករលួយឥណ្ឌូនេស៊ី (KPR)** | **2010** | **2011** | **2012** | **2013** | **2014** | **មធ្យមភាគ** |
| ចំណាយ (គិតជាលានដុល្លារអាមេរិក) | 18.8 | 21.0 | 23.5 | 32.7 | 39.1 | 27.0 |
| កំណើន | - | 12% | 12% | 39% | 20% | 21% |
| ចំណាយសម្រាប់ប្រជាពលរដ្ឋម្នាក់ (គិតជាដុល្លារអាមេរិក) | $0.08 | $0.09 | $0.09 | $0.13 | $0.15 | $0.11 |

*ប្រភព៖ ធនាគារពិភពលោក ទិន្នន័យប្រទេសឥណ្ឌូនេស៊ី: ២០១០-២០១៤ និងច្បាប់ទូទាត់ថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០១៧ និងច្បាប់ថវិកាជាតិឆ្នាំ២០១៨-២០១៩[12, 13, 16]*

## ៦. សន្និដ្ឋាន

ប្រទេសឥណ្ឌូនេស៊ីបាន និងកំពុងតែបោះជំហានយ៉ាងខ្លាំងក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ ដើម្បីកែលម្អប្រព័ន្ធយុត្តិធម៌របស់ខ្លួន និងបង្រ្កាបអំពើពុករលួយ។

កិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មការលុបបំបាត់អំពើពុករលួយ (KPK) របស់ឥណ្ឌូនេស៊ីបានធ្វើអោយ ចំណាត់ថ្នាក់សន្ទស្សន៍ នៃការយល់ឃើញអំពីអំពើពុករលួយ ដែលធ្វើឡើងដោយអង្គការតម្លាភាពអន្តរជាតិជមានភាពប្រសើរឡើង ពីចំណាត់ថ្នាក់ទាបបំផុតក្នុងឆ្នាំ១៩៩៥ ដល់លំដាប់ទី ៨៩ ក្នុងចំណោម ១៨០ ប្រទេស ក្នុងឆ្នាំ ២០១៨ ។

ការចំណាយរបស់ប្រទេសឥណ្ឌូនេស៊ីគិតជាដុល្លារសហរដ្ឋអាមេរិកនៅក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ច្រើនជាងបីដងនៃការចំណាយលើការប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងប្រទេសកម្ពុជា ប៉ុន្តែការចំណាយក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយសម្រាប់ប្រជាពលរដ្ឋម្នាក់នៅប្រទេសឥណ្ឌូនេស៊ី តិចជាងនៅប្រទេសកម្ពុជា (០,១១ ដុល្លារសម្រាប់មនុស្សម្នាក់នៅ ឥណ្ឌូនេស៊ី ទល់នឹង ០,៤៨ ដុល្លារសម្រាប់មនុស្សម្នាក់នៅកម្ពុជា)។

# ឯកសារយោង


1. The World Bank. (2019). *Indonesia Overview* [Online]. Washington, D.C: The World Bank,. Available at: https://www.worldbank.org/en/country/indonesia/overview [Accessed 29 August 2019].
2. The World Bank (2019). Data: Indonesia *In:* The World Bank (ed.) *Population* Washington, D.C.
3. Organizaton for Economic Co-operation and Development (OECD), (2018). *Economic Outlook for Southeast Asia, China and India 2019.* Paris: OECD, Page.1-2. Available at: https://www.oecd.org/development/asia-pacific/01_SAEO2019_Overview_WEB.pdf.
4. PricewaterhouseCoopers, (2015). *The World in 2050: Will the shift in global economic power continue?* , Available at: https://www.pwc.com/gx/en/issues/the-economy/assets/world-in-2050-february-2015.pdf.
5. BPS-Statistics Indonesia, (2018). *Statistical Year Book of Indonesia 2018.* Jakarta BPS-Statistics Indonesia, Page.39. Available at: https://www.bps.go.id/publication/download.html?nrbvfeve=NWE5NjNjMWVhOWIwZmVkNjQ5N2QwODQ1&xzmn=aHR0cHM6Ly93d3cuYnBzLmdvLmlkL3B1YmxpY2F0aW9uLzIwMTgvMDcvMDMvNWE5NjNjMWVhOWIwZmVkNjQ5N2QwODQ1L3N0YXRpc3Rpay1pbmRvbmVzaWEtMjAxOC5odG1s&twoadfnoarfeauf=MjAxOS0wOC0yMiAxNToxMzoyNw%3D%3D [Accessed 22 August 2019].
6. World Justice Project, (2019). *Rule of Law Index 2019.* Washington, D.C: World of Justice Project, Page.54 and 87. Available at: https://worldjusticeproject.org/our-work/research-and-data/wjp-rule-law-index-2019.
7. Transparency International, (2018). *Corruption Perceptions Index 2018.* Berlin: Transparency International, Page.3. Available at: https://www.transparency.org/files/content/pages/CPI_2018_Executive_Summary_EN.pdf.
8. State Ministry of National Development Planning/ National Development Planning Agency (BAPPENAS) (2007). Law on the Republic of Indonesia Number 17 of 2007 on the 2005-2025 Long-Term National Deveopment Plan.
9. Lienert, I., (2015). *Parliamentary Budgeting and Transparency in ASEAN Member States.* AIPA.
10. OECD. (2016). *Indonesia Unitary Country* [Online]. Indonesia. Available at: https://www.oecd.org/regional/regional-policy/profile-Indonesia.pdf [Accessed 28/08 2019].
11. Ministry of Finance of Indonesia (2019). The Implementation Laws 2015-2016 and Budget Laws 2017-2019. People's Representative Council of Indonesia,.
12. MoEF, (2015-2017). *Budget implemnetation* Phnom Penh, Cambodia: Ministry of Economy and Finance, Available at: https://www.mef.gov.kh/tofe.html.
13. MoEF, (2017-2019). *National Budget Law*. Phnom Penh, Cambodia: Ministry of Economy and Finance, Available at: https://www.mef.gov.kh/tofe.html.
14. Extraordinary Chambers in the Courts of Cambodia. (2019). *Frequently Asked Questions About the ECCC* [Online]. Phnom Penh ECCC. Available at: https://www.eccc.gov.kh/km/about-eccc/faq [Accessed 28 August 2019].
15. JD, F. T. T., Phun, V., Kong, F. S. D. R. andSusanti, B., (2016). *Updated Rule of Law for Human Rights in ASEAN: The Path to Integration.* Indonesia: The Human Rights Resource Centre, Available at: https://www.kas.de/c/document_library/get_file?uuid=d188eb27-add2-ad68-5025-118372608c6a&groupId=252038.
16. The World Bank (2017). Ministry Expenditure 2010-2014. *In:* The World Bank (ed.) *2010-2014.* Washington, D.C.
17. Transparency International, (2018). *Indonesia: Overview of corruption and anti-corruption.* Berlin.
18. Anti-Corruption Unit. (2014). *History of the Anti-Corruption Unit* [Online]. Phnom Penh: ACU. Available at: http://www.acu.gov.kh/index.php?4a8a08f09d37b73795649038408b5f33=%E1%9E%91%E1%9F%86%E1%9E%96%E1%9F%90%E1%9E%9A%E1%9E%8A%E1%9E%BE%E1%9E%98&03c7c0ace395d80182db07ae2c30f034=2 [Accessed 23 August 2019].
19. Royal Government of Cambodia (2010). Anti-Corruption Law. Phnom Penh: The National Assembly of Cambodia.

20. Seifert, J. (2015). Information Fact Sheets on Political and Parliamentary Systems of AIPA Member Parliaments. Jakarta: ASEAN Inter-Parliamentary Assembly, 73 p. Available at: http://www.aipasecretariat.org/webassets/pdf/08.pdf [Accessed 4 Sep. 2019].
21. Sherlock, S. (2015). Legislative Procedures of AIPA Member Parliaments. Jakarta: ASEAN Inter-Parliamentary Assembly, 104 p. Available at: http://www.aipasecretariat.org/webassets/pdf/11.pdf [Accessed 4 Sep. 2019].
22. Sherlock, S. (2005). Indonesia's Regional Representative Assembly: Democracy, Representation and the Regions. Canberra: Centre for Democratic Institutions, 48 p. Available at: http://archives.cap.anu.edu.au/cdi_anu_edu_au/_research/2005-06/D_P/DPD%20research%20paper%20Jul%202005.pdf [Accessed 4 Sep. 2019].
23. Sherlock, S. (2007). Parliamentary Indicator-Indonesia. Washington D.C.: World Bank Group, 24 p. Available at: http://documents.worldbank.org/curated/en/249401468188934594/Parliamentary-indicators-Indonesia [Accessed 4 Sep. 2019].